ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគម្រប់បី

ខែ ១២

ក្រុងភ្នំពេញ
រោងពុម្ពរាជការ គូវែរណើម៉ង់
គ្រិ. ឆ្នាំ ១៩៣១
ពុ.ស. ២៤៧៣

អ្នកទទួលខុសត្រូវ ជុំ-ម៉ៅ

# បញ្ជីរឿង

ទំព័រ


១- រឿងមិលិន្ទបញ្ហា ព្រះគ្រូវិមលបញ្ញា អ៊ុម-ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យ កម្ពុជា ប្រែពីបាលីមកជាភាសាខ្មែរ (ត) . . . . .

(មិលិន្ទបញ្ហា មិនបានចុះក្នុងនេះទេ ព្រោះមានបោះពុម្ពសៀវភៅដោយឡែកហើយ) . . . . . . . . .

២- ម្ភៃប្រាំមួយគាថា ដកយកពីគម្ពីរផ្សេងៗ អាចារ្យ យ៉ែម ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ប្រែពីបាលីមកជាភាសាខ្មែរ . . ៣៦៩

៣- រឿងមហាភារត ព្រះមហាពិទូរក្រសេម គន្ធៈបនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែពីភាសាសៀមមកជាភាសាខ្មែរ (ត) . . . ៣៧៨

# ២៦ គាថា

អាចារ្យ ប៉ែម ក្រុមជំនុំព្រះត្រៃបិដក

*ដកយកពីគម្ពីរផ្សេងៗ ហើយប្រែជាភាសាខ្មែរ*

---

## ធីរកថា

១ – អនាគតំ ភយំ ទិស្វា ទូរតោ បរិវជ្ជយេ

អាគតញ្ច ភយំ ទិស្វា អភីតោ ហោតិ បណ្ឌិតោតិ

*(ប្រែ) ជនជាបណ្ឌិតឃើញនូវភ័យដែលមិនទាន់មកដល់ហើយវៀរចាកភ័យនោះអំពីចម្ងាយ បើប្រសិនណាឃើញនូវភ័យនោះមកដល់ហើយក៏មិនមានភ័យ* (លោកនីតិ)

២ · យថា សេលោ ឯកឃនោ វាតេន ន សមីរតិ

ឯវំ និន្ទាបសំសាសុ ន សមិញ្ជន្តិ បណ្ឌិតាតិ

*(ប្រែ) ថ្ម១ដុំមិនញាប់ញ័រដោយខ្យល់យ៉ាងណា ជនទាំងឡាយជាបណ្ឌិតមិនញាប់ញ័រ ក្នុងពាក្យនិន្ទា និងពាក្យសរសើរទាំងឡាយយ៉ាងនោះ* (វិសុទ្ធមគ្គ)

៣ · ឯវំ អនិច្ចតំ ជម្មិ ញត្វា ធុរភិសម្ភុំ

តំ បត្តុំ វាយមេ ធីរោ យំ និច្ចំ អមតំ បទន្តិ

*(ប្រែ) ជនជាអ្នកប្រាជ្ញមានប្រាជ្ញាជាគ្រឿងទ្រទ្រង់ ដឹងហើយ*

នូវអនិច្ចតាធម៌ ដែលជាធម៌លាមកយ៉ាងនេះ គឺបុគ្គលឆ្លងបានដោយកម្រ ផ្លូវនៃព្រះនិព្វានដែលទៀងមិនស្លាប់ឯណា ខំព្យាយាម ដើម្បីដល់ផ្លូវនៃព្រះនិព្វាននោះ (បឋមសាមន្ត)

៤ – នាទិដ្ឋា បរតោ ទោសំ អណុំថូលានិ សព្វសោ
ឥស្សរោ បណយេ ទណ្ឌំ សាមំ អប្បដិវេក្ខិយាតិ

(ប្រែ) ជនជាធំមិនឃើញនូវទោសតូច ទាំងទោសធំ អំពីបុគ្គលដទៃ ហើយមិនទាន់ពិចារណាសព្វគ្រប់ដោយខ្លួនឯង មិនត្រូវធ្វើអាជ្ញាទេ (ធម្មបទ)

៥ – ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ
អប្បស្សាទា ទុក្ខា កាមា ឥតិ វិញ្ញាយ បណ្ឌិតោតិ

(ប្រែ) ធម្មជាតិជាហេតុឆ្អែតក្នុងកាមគុណទាំងឡាយ ៥ មិនមានដោយអំណាចនៃកហាបណ ជនជាបណ្ឌិតដឹងច្បាស់ដូច្នេះថា កាមគុណទាំងឡាយ ៥ មានសេចក្ដីជ្រះថ្លា មិនមានរមែងតែងនាំមកនូវទុក្ខជាដរាប (ធម្មបទ)

៦ – អបិ ទិព្វេសុ កាមេសុ រតិំ សោ នាធិគច្ឆតិ
តណ្ហក្ខយរតោ ហោតិ សម្មាសម្ពុទ្ធសាវកោតិ

(ប្រែ) ម្យ៉ាងទៀតជនជាបណ្ឌិតជាសាវកព្រះសម្មាសម្ពុទ្ធនោះ មិនដល់ក្រៃពេកនូវសេចក្ដីត្រេកអរ គឺថាមិនលុះក្នុងអំណាចកាមគុណទាំង

ឡាយ ៤ ដ៏ជាទិព្វ ព្រោះអរតែក្ខ័យធម៌ជាគ្រឿងអស់ទៅនៃតណ្ហា (ធម្មបទ)

៧ – ធម្មបីតិ សុខំ សេតិ  វិប្បសន្នេន ចេតសា
អរិយប្បវេទិតេ ធម្មេ  សទា រមតិ បណ្ឌិតោតិ

(ប្រែ) ជនជាបណ្ឌិតមានចិត្តជ្រះថ្លា ហើយដោយវិសេសផឹកនូវរស នៃព្រះនព្វលោកុត្តរធម៌ដេកជាសុខ ព្រោះអរក្នុងពោធិបក្ខិយធម៌ គឺព្រះអរិយទាំងឡាយមានព្រះពុទ្ធជាដើម សម្ដែងហើយក្នុងកាលទាំងពួង (ធម្មបទ)

៨ – យថាបិ រហទោ គម្ភីរោ  វិប្បសន្នោ អនាវិលោ
ឯវំ ធម្មានិ សុត្វាន  វិប្បសីទន្តិ បណ្ឌិតាតិ

(ប្រែ) អន្លង់ទឹកជ្រៅថ្លាមានល្អក់មិនមានយ៉ាងណា ជនទាំងឡាយ ជាបណ្ឌិតស្ដាប់នូវធម៌ទេសនាទាំងឡាយ ហើយជ្រះថ្លាដោយវិសេស យ៉ាងនោះ (ធម្មបទ)

៩ – ឧទកំ ហិ នយន្តិ នេត្តិកា  ឧសុការា នមយន្តិ តេជនំ
ទារុំ នមយន្តិ តច្ឆកា  អត្តានំ ទមយន្តិ បណ្ឌិតាតិ

(ប្រែ) សេចក្ដីពិតថា អ្នកធ្វើស្រែទាំងឡាយនាំទៅនូវទឹក ជាងកូនសរទាំងឡាយពត់នូវកូនសរ ជាងចាំងទាំងឡាយចាំងនូវឈើ ជនទាំងឡាយជាបណ្ឌិតទូន្មាននូវខ្លួន (ធម្មបទ)

១០ – អនុបុព្វេន មេធាវី  ថោកំ ថោកំ ខណេ ខណេ
កម្មារោ រជតស្សេវ  និទ្ធមេ មលមត្តនោតិ

(ប្រែ) ជនជាបណ្ឌិតមានប្រាជ្ញាជាគ្រឿងទំលាយបង់នូវកិលេស គប្បីធ្វើនូវការជាកុសលបន្តិចៗ (គឺជាធ្វើញយៗ) ក្នុងខណៈឬក្នុងឱកាស គប្បីកម្ចាត់បង់នូវមន្ទិលមានរាគជាដើមនៃខ្លួនចេញ ដូចជាជាងមាសកាលដុតហើយដុំនូវមាស គប្បីទាញយកនូវមន្ទិលនៃមាសនោះចេញ (ធម្មបទ)

## ពុទ្ធកហា

១១ – តិណទោសានិ ខេត្តានិ រាគទោសា អយំ បជា
តស្មា ហិ វីតរាគេសុ ទិន្នំ ហោតិ មហប្ផលំ

(ប្រែ) ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វនេះមានរាគជាទោស ព្រោះហេតុដូច្នោះពិត ទានដែលបុគ្គលឲ្យហើយដល់បុគ្គលទាំងឡាយ មានរាគទៅប្រាសហើយ ជាទានមានផលច្រើន (ធម្មបទ)

១២– តិណទោសានិ ខេត្តានិ ទោសទោសា អយំ បជា
តស្មា ហិ វីតទោសេសុ ទិន្នំ ហោតិ មហប្ផលំ

(ប្រែ) ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វនេះមានទោសជាទោស ព្រោះហេតុដូច្នោះពិត ទានដែលបុគ្គលឲ្យហើយដល់បុគ្គលទាំងឡាយ មានទោសទៅប្រាសហើយ ជាទានមានផលច្រើន (ធម្មបទ)

១៣ – តិណទោសានិ ខេត្តានិ មោហទោសា អយំ បជា
តស្មា ហិ វីតមោហេសុ ទិន្នំ ហោតិ មហប្ផលំ

(ប្រែ) ស្រែតាំងឡាយមានស្មៅជាទោស ពួកសត្វនេះមានមោហៈ
ជាទោស ព្រោះហេតុដូច្នោះពិត ទានដែលបុគ្គលឲ្យហើយដល់បុគ្គលតាំង
ឡាយ មានមោហៈទៅប្រាសហើយ ជាទានមានផលច្រើន (ធម្មបទ)

១៤– តិណទោសានិ ខេត្តានិ ឥច្ឆាទោសា អយំ បជា
តស្មា ហិ វិគតិច្ឆេសុ ទិន្នំ ហោតិ មហប្ផលំ

(ប្រែ) ស្រែតាំងឡាយមានស្មៅជាទោស ពួកសត្វនេះមាន
សេចក្តីប្រាថ្នាជាទោស ព្រោះហេតុដូច្នោះពិត ទានដែលបុគ្គលឲ្យ
ហើយដល់បុគ្គលតាំងឡាយ មានសេចក្តីប្រាថ្នាទៅប្រាសហើយជា
ទានមានផលច្រើន (ធម្មបទ)

## សំវរកថា

១៥– កាយប្បកោបំ រក្ខេយ្យ កាយេន សំវុតោ សិយា
កាយទុច្ចរិតំ ហិត្វា កាយេន សុចរិតំ ចរេ

(ប្រែ) បុគ្គលត្រូវរក្សានូវកិរិយាកម្រើកឡើងនៃកាយទុច្ចរិតតាំង ៣
ប្រការ ត្រូវសង្រួមដោយប្រពៃ ដើម្បីបិទនូវកាយទុច្ចរិតតាំង ៣ ប្រការ
នោះ មិនឲ្យចូលមកតាមកាយទ្វារបាន ត្រូវលះបង់កាយទុច្ចរិតតាំង ៣
នោះចេញ ហើយប្រព្រឹត្តកាយសុចរិតទាំង ៣ ប្រការវិញ (ធម្មបទ)

១៦ វចីបកោបំ រក្ខេយ្យ វាចាយ សំវុតោ សិយា
វចី ទុច្ចរិតំ ហិត្វា វាចាយ សុចរិតំ ចរេ

(ប្រែ) បុគ្គលត្រូវរក្សានូវកិរិយាកម្រើកឡើង នៃវចីទុច្ចរិតទាំង ៤ ប្រការ ត្រូវសង្រួមដោយប្រពៃ ដើម្បីបិទនូវវចីទុច្ចរិតទាំង ៤ ប្រការនោះ មិនឲ្យចូលមកតាមវចីទ្វារបាន ត្រូវលះបង់វចីទុច្ចរិតទាំង ៤ ប្រការនោះចេញ ហើយប្រព្រឹត្តសុចរិតទាំង ៤ ប្រការវិញ (ធម្មបទ)

១៧– មនោបកោបំ រក្ខេយ្យ មនសា សំវុតោ សិយា
មនោទុច្ចរិតំ ហិត្វា មនសា សុចរិតំ ចរេ

(ប្រែ) បុគ្គលត្រូវរក្សានូវកិរិយាកម្រើកឡើងនៃមនោទុច្ចរិតទាំង ៣ ប្រការ ត្រូវសង្រួមដោយប្រពៃ ដើម្បីបិទនូវមនោទុច្ចរិតទាំង ៣ ប្រការនោះ មិនឲ្យចូលមកតាមមនោទ្វារបាន ត្រូវលះបង់មនោទុច្ចរិតទាំង៣ ប្រការនោះចេញ ហើយប្រព្រឹត្តមនោសុចរិតទាំង ៣ ប្រការវិញ (ធម្មបទ)

១៨ កាយេន សំវុតា ធីរា អថោ វាចាយ សំវុតា
មនសា សំវុតា ធីរា តេ វេ សុបរិសំវុតា

(ប្រែ) អ្នកប្រាជ្ញទាំងឡាយ មានប្រាជ្ញាជាគ្រឿងទ្រទ្រង់សង្រួមហើយដោយប្រពៃនូវកាយទ្វារ ម្យ៉ាងទៀតអ្នកប្រាជ្ញទាំងឡាយមានប្រាជ្ញាជាគ្រឿងទ្រទ្រង់ សង្រួមហើយដោយប្រពៃនូវវចីទ្វារ អ្នកប្រាជ្ញទាំងឡាយមានប្រាជ្ញាជាគ្រឿងទ្រទ្រង់ សង្រួមហើយដោយប្រពៃនូវមនោទ្វារ អ្នកប្រាជ្ញទាំងឡាយមានប្រាជ្ញា ជាគ្រឿងទ្រទ្រង់នោះឯង ឈ្មោះថា មានកាយទ្វារ វចីទ្វារនិងមនោទ្វារគ្រប់គ្រងហើយ សង្រួមប្រពៃហើយ (ធម្មបទ)

# សំវេគកថា

១៩ សព្វេសំខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយាតិ

(ប្រែ) អ្នកឯណាឃើញដូច្នេះថា សង្ខារទាំងឡាយទាំងពួងមិនទៀង (តែងកើតឡើងហើយវិនាសទៅជាធម្មតា) ដោយប្រាជ្ញាក្នុងកាលឯណា អ្នកនោះនឿយណាយក្នុងសេចក្តីទុក្ខដែលប្រព្រឹត្តទៅក្នុងភពទាំង ៣ ក្នុងកាលនោះ សភាវគឺបណ្ឌិតពោលថា សេចក្តីនឿយណាយនេះ ជាឧបាយជាហេតុដល់នូវអមតមហានិព្វាន (វិសុទ្ធិមគ្គ)

២០- សព្វេសំខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយាតិ

(ប្រែ) អ្នកឯណាឃើញដូច្នេះថា សង្ខារទាំងឡាយទាំងពួងតែងនាំមកនូវសេចក្តីទុក្ខជាដរាប ដោយប្រាជ្ញាក្នុងកាលឯណា អ្នកនោះនឿយណាយក្នុងសេចក្តីទុក្ខ ដែលប្រព្រឹត្តទៅក្នុងភពទាំងបីក្នុងកាលនោះ សភាវគឺបណ្ឌិតពោលថាសេចក្តីនឿយណាយនេះ ជាឧបាយជាហេតុដល់នូវអមតមហានិព្វាន (វិសុទ្ធមគ្គ)

២១- សព្វេសំខារា អនត្តាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយាតិ

(ប្រែ) អ្នកឯណាឃើញដូច្នេះថា សង្ខារទាំងឡាយទាំងពួងមិនមែនជារបស់នៃខ្លួនដោយប្រាជ្ញាក្នុងកាលឯណា អ្នកនោះនឿយណាយក្នុងសេចក្តីទុក្ខ ដែលប្រព្រឹត្តទៅក្នុងភពទាំងបីក្នុងកាលនោះ សភាវគឺបណ្ឌិតពោលថា សេចក្តីនឿយណាយនេះជាឧបាយជាហេតុដល់នូវអមតមហានិព្វាន (វិសុទ្ធិមគ្គ)

## បិយកថា

២២- បិយតោ ជាយតេ សោកោ បិយតោ ជាយតេ ភយំ

បិយតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយន្តិ

(ប្រែ) សេចក្តីសោកកើតមកអំពីសត្វនិងសង្ខារ ជាទីស្រឡាញ់ សេចក្តីភ័យកើតមកអំពីសត្វនិងសង្ខារជាទីស្រឡាញ់សេចក្តីសោកមិនមានដល់បុគ្គលដែលមានចិត្តផុតស្រឡះ ហើយចាកសត្វនិងសង្ខារជាទីស្រឡាញ់ សេចក្តីភ័យមានមកអំពីឯណា (ធម្មបទ)

២៣ បេមតោ ជាយតេ សោកោ បេមតោ ជាយតេ ភយំ

បេមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយន្តិ

(ប្រែ) សេចក្តីសោកមកអំពីសេចក្តីស្រឡាញ់ សេចក្តីភ័យកើតមកអំពីសេចក្តីស្រឡាញ់ សេចក្តីសោកមិនមានដល់បុគ្គលដែលមានចិត្តផុតស្រឡះហើយ ចាកសេចក្តីស្រឡាញ់សេចក្តីភ័យមានមកអំពីទីឯណា (ធម្មបទ)

២៤– រតិយា ជាយតេ សោកោ  រតិយា ជាយតេ ភយន្តិ
រតិយា វិប្បមុត្តស្ស  នត្ថិ សោកោ កុតោ ភយន្តិ

(ប្រែ) សេចក្ដីសោកកើតមកអំពីសេចក្ដីតម្រេក ក្នុងកាមគុណ ៥ សេចក្ដីភ័យកើតមកអំពីសេចក្ដីតម្រេកក្នុងកាមគុណ ៥ សេចក្ដីសោកមិនមានដល់បុគ្គល ដែលមានចិត្តផុតស្រឡះ ហើយចាកសេចក្ដីតម្រេកក្នុងកាមគុណ ៥ សេចក្ដីភ័យមានមកអំពីទីឯណា (ធម្មបទ)

២៥ កាមតោ ជាយតេ សោកោ  កាមតោ ជាយតេ ភយំ
កាមតោ វិប្បមុត្តស្ស  នត្ថិ សោកោ កុតោ ភយន្តិ

(ប្រែ) សេចក្ដីសោកកើតមកអំពីវត្ថុកាម និងកិលេសកាម សេចក្ដីភ័យកើតមកអំពីវត្ថុកាមនិងកិលេសកាម សេចក្ដីសោកមិនមានដល់បុគ្គលដែលមានចិត្តផុតស្រឡះ ហើយចាកវត្ថុកាមនិងកិលេសកាម សេចក្ដីភ័យមានមកអំពីទីឯណា (ធម្មបទ)

២៦ តណ្ហាយ ជាយតេ សោកោ  តណ្ហាយ ជាយតេ ភយំ
តណ្ហាយ វិប្បមុត្តស្ស  នត្ថិ សោកោ កុតោ ភយន្តិ

(ប្រែ) សេចក្ដីសោកកើតមកអំពីសេចក្ដីចំណង់ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ សេចក្ដីភ័យកើតមកអំពីសេចក្ដីចំណង់ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ សេចក្ដីសោកមិនមានដល់បុគ្គលដែលមានចិត្តផុតស្រឡះ ហើយចាកសេចក្ដីចំណង់ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ សេចក្ដីភ័យមានមកអំពីទីឯណា (ធម្មបទ)

# រឿងមហាភារតយុទ្ធ

ព្រះមហាពិទូរក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា

រៀបរៀង

(៣)

---

## ភាគដំបូង

## ទ្រោណាចារ្យអ្នកនាំទ័ពថ្មីខាងកុរុ

ថ្ងៃ តពីនេះទៀត តអំពីការដួលនៃភីស្មៈ មន់ជ័យរំពួលកាលនៃទ្រោណាចារ្យ បានទៅប្រ[illegible] ហ្មទយ៉ាងបញ្ញា: បង្ហាញយុទ្ធ បម្ដង:គ្រឿងសម្គាល់ប្រចាំជាតិ ដែលមហាជនតែងស្គាល់ គ្រប់តែការគ្នា គឺបុណ្ណព្រៃឌី តាំងនៅលើស្បែកម្រឹគ ព្រៃឌីនោះ ក្រាបបញ្ជិតនាគរបស់គេស្បែកម្រឹគប្រាប់បញ្ជិតគរបស់គេ ព្រោះព្រាហ្មណាចារ្យតាំងតួនក្នុងសម័យឥណ្ឌាបុរាណជា អណោគ៍សនកាប្រែ[illegible] នាក្នុងដែនព្រៃស្ងាត់ចាកពពួកមនុស្សគ្មានការឡោះកាល័យក្នុងផ្លូវលោកិយដូចម្ដេច រៀនលេងតែប្រជាធម៌ និងចំណេះវិជ្ជាសម្រាប់លោកខ្លះ ដល់អន្តេវាសិកកម្លោះៗ អ្នកមានបារិតបម្រូមកនៅតាមពេមជាសិស្ស ។

ទ្រោណមុនបានទទួលដំណែងជាមេទ័ព គេបានពោលពាក្យបដិញ្ញា

ចំពោះទុរយោធន៍ថា គេនឹងទៅយកខ្លួនយុធិស្ឋិរដាក់គ្រឿងពន្ធនាគារមក កាន់បន្ទាយកុរុឲ្យបាន ។

អរជុនបានស្តាប់ពាក្យបដិញ្ញាមុខគួរខ្លាចនេះ ក៏ទូលយុធិស្ឋិរថា លោកគាចារ្យចាស់របស់យើងនោះ ជាបុគ្គលសក្តិសិទ្ធិ យើងនឹងយកជ័យគេមិនបានក្នុងការសង្គ្រាម មើលទៅដូចជាថាអ្នកណាក៏ដោយ គាប់នឹងសម្លាប់បានទាំងអស់គ្មានកំណត់រើសមុខ ខុកអ្នកនេះ សម្លាប់អ្នកនោះៗទេ តែម្តងយើងសម្លាប់គេក្នុងសង្គ្រាមវាំងបង់ប្អូននេះក៏មិនបាន ទោះបង្ហោះក្តី ពាក្យដែលគេបដិញ្ញាទុកនោះ ជាពាក្យបដិញ្ញាមុខគួរព្រឺ តែខ្ញុំសុំបដិញ្ញាតនឹងពាក្យបដិញ្ញារបស់លោកគ្រូគាចារ្យថា ដរាបណាលោហិតរបស់ខ្ញុំនៅមានសូម្បីមួយដំណក់ក្នុងកាយរបស់ខ្ញុំ វរកាយរបស់យុធិស្ឋិរនឹងមិនត្រូវភ័យអន្តរាយ សូម្បីពេម ១ សរសៃដរាបនោះ ទោណនឹងចូលមកជ័តអង្គុយ យុធិស្ឋិរមិនបានជាដាច់ខាត វៀរលែងតែដើរជិះជាន់លើសពអរជុនចូលមក ។

មុននឹងឡើងរថសឹក គាចារ្យទោណបានបម្រើនការទាមួយបទដល់ទេវតា នឹងពោលសុំនូវពរចាស់ជឿនទាហានរបស់គេពីរបីម៉ាត់ រឿងពោលក្រោយមានសេចក្តីដូចតទៅនេះ ៖

ទាហានទាំងឡាយ កិត្តិយសនៃការនាំទាហានដ៏ក្លាធ្លាក់ជាភារៈលើយើងក្នុងថ្ងៃនេះ ការទទួលខុសត្រូវក្នុងពជការសង្គ្រាមធ្លាក់មកលើយើង

ទាំងមូល តេជគុណបុណ្យព្រះជួយ ឲ្យជ័យយើងមានសេចក្ដីសង្ឃឹមពេញទីថា ម្ដងនេះសង្គ្រាមនឹងសូន្យទៅដោយថ្វីដៃជ័យជម្នះរបស់កុរុ តែទឹងណែគ្មានមេទ័ពនាយពលណា សូម្បីក្លាហានជាញជ័យដូចម្ដេចក្ដីនឹងអាចជ័យជម្នះ ដោយចំពោះខ្លួនបានឡើយ តោងអាស្រ័យសេចក្ដីព្រមព្រៀងអស់បណ្ដាពល ទាហានជ្រំជ្រែងពេញសតិកម្លាំងជួយគ្នាកម្ចាត់បច្ចាមិត្រ ទើបនឹងយកជ័យជំនះបាន ដោយប្រការនេះអ្នកទាំងឡាយចូលដឹងថា កិត្តិយសរបស់ព្រះមហាក្សត្រិយ៍ និងស្រុកទេសរបស់អ្នក សេចក្ដីនិកសភ័យនៃគ្រួសាររបស់អ្នក រមែងអាស្រ័យកម្លាំងកាយកម្លាំងសតិបញ្ញាអ្នកពលគ្នា ជាការផ្គុំផ្ដាក់លើអ្នកពលគ្នា មិនមែនស្ថិតនៅលើឯកជន សុំឲ្យទាហានទាំងឡាយ កត់សម្គាល់រឿងនេះទុកក្នុងចិត្តរបស់ខ្លួន នឹងសុំឲ្យធ្វើមុខការនាទីរបស់ខ្លួនយ៉ាងកូនប្រុស មិនត្រូវទៅគិតនឹកដល់ផលក្នុងទីបំផុត ។

ក្នុងថ្ងៃដំបូងដែលទោណាចារ្យ ទទួលដំណែងជាអ្នកបញ្ជាការ អភិមន្យុបុត្រអរជុន បានសម្ដែងថ្វីដៃឯកប្លែកជាងគេក្នុងការចម្បាំង សម្ដែងសេចក្ដីក្លាហានឃើញប្រាកដនឹងភ្នែកម្ដងហើយម្ដងទៀត សម្ដែងខ្លួនជាអ្នកចម្បាំងឯកក្នុងជំនាន់ក្មេងទើបនឹងទ្រើសឡើង នឹងជាអ្នកធំទៅខាងមុខ ការតស៊ូដណ្ដើមជ័យគ្នាក្នុងថ្ងៃនេះ គឺច្បាំងនឹងកុរុកជាមួយគន្ធ្រង់នាមបៅរពអភិមន្យុបាចកន្ទ្រាក់បៅរពម្នាក់អំពីពជរថ គ្រវាត់

ដួលប្រហិតប្រហែម ជ័យទ្រថក្សត្រិយ៍សិន្ធុកាលឃើញព្រះចៅបៅរពក្ខាក់ទៅក្នុងភ័យ ក៏មិនមាចូលទៅជួយដោយស្រេកទន់ បានរះក្របីគ្នាទីងអកិ-មន្យុ ធាតហើយធាតទៀត អ្នកធ្វើការគសីត្នាទាំងពីរប្រោណមិនអាចកាប់គ្នាត្រង់ណាបានដោយស្មៀតញឹកស៊ើគ្នា បន្តិចជ័យទ្រថលុតជង្គង់ចុះចាក់សំដៅដើមទ្រូងអកិមន្យុ តែអកិមន្យុគាត់ទាន់ ក្របីចង្កិចគ្នាឲ្យតែធាតៗ ក្របីរបស់ជ័យទ្រថបាក់ពាក់កណ្ដាល ជ័យទ្រថក៏រត់ឡើងរថសឹកបរចេញទៅអំពីស្មាមយុទ្ធទុកឲ្យកុរុជាមួយអង្គទ្រង់នាមសល្យ និងព្រះចៅក្រុងមាទ្រចូលតយុទ្ធគ្នានឹងអកិមន្យុ ។

ក្នុងខណៈនោះមានទាហានក្នុណ្ឌពមួយកង មកជួយអកិមន្យុ ក៏មកាន់ដំបងមួយយ៉ាង ខាងចុងមានបន្លាជាបន្លាទុរេនគ្រីគ្រវត់ចូលទៅរះគ្នាក្តួតក្តួនិងសល្យ ទាំងពីរស្ទាត់ក្នុងការប្រើដំបងដូចគ្នា ឲ្យតែស្បូវដែលថ្លាស់គ្នាវាយម្ដងម្នាក់ ឲ្យតែស្បូវហោក់ដូចសិង្ហគោប្រខាំគ្នា ទាំងពីរអង្គ ក៏ឈើ បំភ័ត ជីងវែងដ៏ក្រ ញូងកំញញ្ញហឹ ក ម្នាក់ការុង ដៃម្នាក់វាយមកឲ្យស្រោលចុះ ដូចយ៉ាងខ្យល់បក់មកឲ្យស្រោលកាយ ការគសីគ្នាតែខ្លាំងឡើងៗ តែពោះបំផ្លូចទាះ អ្នក ម្សាំងទាំង ពុំ ម្ចិ ក្រូចថដ សូម្បីមួយជំហាន ពេះតែស្បូវក់ស្លេះគ្នាក្ដួតទីង ។ ទំពាំងខាងណាមួយនឹងដួលនៅ ក្នុងទីបំផុតក៏ចម្លូលដួលផ្ដាប់មុខទាំងពីរ តែក៏មក្រោកឡើងបានមុនលោលើកដំបងឡើងនឹងប្រហារ លុះឃើញជ័យទ្រថមានលោហិតហូរ

ប្រហែលសន្លប់បាត់ស្មារតី ក៏អនុញ្ញាតឲ្យមនុស្សស្រែងទៅរកកងព្យាបាល ដើម្បីហាត់ការតទៅ ។

ក្នុងភាគខ្មាងនៃសង្គាមយុទ្ធនោះ ទោណាចារ្យកំពុងធ្វើការប្រយុទ្ធនឹងបច្ចាមិត្រ លុះគេក្រឡេកទៅឃើញយុធិស្ឋិរតែម្នាក់ឯង គ្មានអ្នកណាការពារព្រះអង្គ គេក៏បររថចូលទៅ ដើម្បីនឹងប្រតិបត្តិតាមពាក្យបញ្ជា ដែលថា "នឹងឃុំខ្លួនយុធិស្ឋិរទៅកាន់បន្ទាយកុរុឲ្យបាន" ទាហានពួកបាណ្ឌពឃើញទោណាចារ្យបររថសំដៅទៅ ក៏ស្រែកតៗគ្នាលាន់ទាំងសង្គាមយុទ្ធ ដើម្បីឲ្យប្រុងប្រយ័ត្ន អរជុនដឹងថាព្រះរាជារបស់ខ្លួនធ្លាក់នៅក្នុងទីមានភ័យ ក៏ប្រញាប់ទៅជួយដោយរួសរាន់ បរសិន្ធពដ៏លឿនស្ទុះសំដៅទៅរកយុធិស្ឋិរ បន្តិចអរជុនក៏ដេញមុខបាន ពេលមេទ័ពកុរុនៅខាងក្រោយ ទៅដល់ខាងអង្គុយយុធិស្ឋិរមុនទោណាធ្វើការការមិនឲ្យទោណាចូលទៅយាយីបាន ។

ក្នុងភាគដទៃនៃសង្គាមយុទ្ធ មានការតស៊ូគ្នាដោយអន្ទើរមិនបែកទីងថ្ងៃមុន ក្រប៉ឹងក្រប៉ះគ្នាឮតែញ៉ាំង ៗ ដួនបាក់ជាកំណាត់ ៗ សេះសឹកដួលដេកប្រកាច់លើផែនពសុធា រថសឹកបាក់ប្រេកកង់បួន ខ្ចាត់ខ្ចាយដំរីសឹកស្រែកថ្ងូរកំរើកប្រមោយកន្ទុយ បោលៈខ្ចាត់ពាសទីយុទ្ធភូមិ ។

តែរឿងអស់នេះមិនមែនមានតែក្នុងថ្ងៃនេះ ក្នុងថ្ងៃមុន ៗ ក៏មែន

មានមកហើយ ជាពាក្យពោលដដែល ៗ និងពណ៌នាឲ្យល្អិតសព្វគ្រប់ទៅ ជាហេតុធ្វើឲ្យសាបសេចក្តី ការកាប់សម្លាប់គ្នាជារឿងធម្មតារបស់ការសង្គ្រាម ការរត់និងដេញ ការបែកទ័ព និងការត្រឡប់ផ្តុំចូលជាកងឡើងវិញ សំឡេងស្រែកជាមានជ័យ សំឡេងអ្នកត្រូវរបួសស្រែកថ្ងូរ សំឡេងស្រែកជាប្រឹងឡើង សំឡេងពន្យុះឲ្យចូលវាយ គម្លាលនេះជាការប្រចាំថ្ងៃ ដែលអ្នកបុរាណគតិសូម្បីជាអ្នកល្អិត ក៏មិនបង់ពណ៌នាឲ្យពិស្តារទុក លំដាប់នោះវេលាព្រឹកក៏បរចូលមកដល់ ត្រែខ្វីក៏បន្លឺសព្ទសញ្ញាឈប់ច្បាំងមួយលើកទៀត ។

ព្រឹកឡើងទោណាបានព្យាយាមធ្វើការ ប្រាថ្នានឹងចាប់ខ្លួនយុធិស្ឋិរឲ្យបាន តាមពាក្យបដិញ្ញារបស់គេ គេនាំកងពលហានទាំងមូលចូលទៅសំដៅតែមួយយ៉ាង គឺនឹងចាប់យុធិស្ឋិរព្រមព្រួតទាំងអស់បាញ់ចំពោះតែយុធិស្ឋិរ ដោយបំណងយ៉ាងធំ នឹងកាប់យុធិស្ឋិរឲ្យរាប ហើយចាប់យកខ្លួនទោបនាយ ជាឧបាយ ដើម្បីនឹងចាប់យុធិស្ឋិរឲ្យកាយរៀង គេទើបជន្ទ្រឲ្យអរជុនឃ្លាតចេញអំពីយុធិស្ឋិរ ដោយឲ្យសុសរម៉ែនទៅបបួលច្បាំងតតួ អរជុនទទួលច្បាំងតតួ តែភ្នែករំពៃមើលមកតែឯយុធិស្ឋិរព្រោះគេយល់ល្បិចដ៏ជ្រៅនៃការល្បួងច្បាំង និងនឹកដល់ពាក្យបដិញ្ញារបស់ទោណានៅជាទិច្ច បានតយុទ្ធគ្នានឹងសុសរម៉ែន ហើយត្រឡប់មកធ្វើនាទីរាំងរក្សាយុធិស្ឋិរ ។

ខណៈដែលគោណលើកទ័ពតម្រង់ទៅ នឹងបង្ក្រាបយុធិស្ឋិរកងទ័ព ធំកុរុមិនបាននៅទេ ក្សត្រិយ៍កុរុជាច្រើនអង្គក៏បានបាត់ការបំបែកញែក គ្នា ចូលវាយកងទ័ពបាណ្ឌពជាច្រើន ព្យាយាមដូច្នោះ ដើម្បីនឹងវាយ ឲ្យបែកកក់កាយទៅ និងបានចាប់យុធិស្ឋិរបានដោយងាយ ទុរយោធន៍ ចូលមកវាយភីម តែចូលច្បាំងបានមួយស្របក់ក៏ត្រូវអាវុធ តោងថយ ទៅអំពីស្នាមយុទ្ធ អរជុនសង្កេតឃើញការរួមកម្លាំងដ៏ខ្លាំងនៃការព្រួត វាយរបស់កុរុ ដ៏ហូរមកប៉ដូចជាលលកទឹក គេក៏សម្រុកចូលវាយពាក់ កណ្តាលថៃមុខ ៗ បែកទៅម្តងមួយថៃៗ ខ្ចាត់ខ្ចាយកាយជាពួកតូច ៗ រួមគ្នាជាកងទ័ពវិញមិនបាន ខ្លះទៅលិច ខ្លះទៅកើត នេះជាថ្ងៃដែលយ៉ាង ឯក ជាស្នាមដៃមានគ្រូ ធ្វើការក្រុមកនៃកងទ័ពកុរុឃើញយូរធ្វើការមិន សម្រេចផលដូចបំណង កណ៌ឃើញដូច្នោះ ចិត្តរបស់គេដែលគេមាន ព្យាបាទ នឹងប្តូរស្រាពេញប្រៀប មិនអាចនឹងទប់រំងាប់បានក៏រហោចចូល វាយអរជុន ដោយមិនគិតជីវិតជារស់ឬស្លាប់ តាំងចិត្តតែនឹងយកជ័យ ឬលះជីវិតជាកដពលីសម្រាប់ផែនដីប៉ុណ្ណោះ បានតស៊ូគ្នាជាយូរ ពុស្សូ សន្ធឹកតឹកកង តែកណ៌ក្តី អរជុនក្តី គ្មានអ្នកបានជ័យអំពីគ្នា អ្នក ទាំងពីរប្រហាណប្រដំប្រសងគ្នាទាំងសងខាង មានសេចក្តីពេញចិត្តនឹង ខ្លួនឯង ដែលផ្លាស់គ្នាវាយផ្លាស់គ្នាទទួលរង គ្មានបាញ់ប្រៀបគ្នាត្រង់ ណា រហូតដល់ព្រលប់ក៏តោងលះលើកគ្នាវៀងខ្លួន ។

# ភាគដប់ប្រាំ

## មរណៈនៃ អភិមន្យុ

ថ្ងៃទីដប់ពីរ នៃយុទ្ធការរៀងរះឡើងមក ពេលនោះគេមានចិត្តរីករាយក្រៃពេក កម្លាំងរបស់គេក៏នៅមានបរិបូណ៌ កម្លាំងរេហ៍ពលសោតក៏នៅមិនទាន់រលោះអស់ គេចាត់កងទាហានថ្ងៃនេះជារូបសរសៃមងពីងពាង ដើម្បីធ្វើឲ្យក្រាស់ក្រួនជួនការសឹក រាយមកទឹងមិនធ្លុះចូលទៅបាន រៀវលែងតែចូលទៅស្លាប់ ឬត្រូវចាប់ខ្លួន ក្បួនទ័ពច្រើនជាន់យ៉ាងដែលពោលមកហើយនោះ ជាយុទ្ធកិច្ចប្រកណារបស់ទ្រោណ តែតាមធម្មតាកលល្បាលនេះ ច្រើនយកមកប្រើក្នុងវេលាដែលឃើញថាគ្មានផ្លូវផ្សេងម្ដេចហើយ ដើម្បីទឹងបញ្ឆោតឲ្យអរជុនចូលទៅក្នុងទីដែលគេធ្វើកលខ្ទុក ទើបពោលសម្ដីទៅដល់អរជុនដូចកាលថ្ងៃមុន អរជុនគ្រេះរះយល់ឧបាយនោះ ដែលមានសេចក្ដីដូចគ្នា នឹងសម្ដីឧបាយកលពីងពាង អញ្ជើញក្រុយថា អញ្ជើញចូលមកក្នុងបន្ទប់ខ្ទួលកៀររបស់ខ្ញុំ ជាអរជុនទទួលពាក្យបបួលច្បាំង តែមិនពោលនាទីរបស់ខ្លួន ទើបប្រើអភិមន្យុជាបុត្រទៅតស៊ូជំនួស អ្នកចម្បាំងកំឡោះត្រេកអរពន់ប្រមាណ ដែលបានទទួលនាទីធ្វើការជំនួសបិតាដូច្នោះ ក៏ស្រូកន់ឡើងរថសឹកគគ្រឹកត្រង់ទៅទិសសឹក ហាក់បីដូចជាទៅបោសកងទ័ពកុរុឲ្យរលីងទៅដោយ

ការក្រោកនៃតម្កួន ដើម្បីនឹងក្រោកឆ្ពួលទៅបាញ ទុរយោធន៍ក៏ចូលមកការ ពារដោយកម្លាំងដ៏មហិមា តែកាលបះគ្នាមួយគ្រួសទៅ អភិមន្យុបាន ផ្ញើប្ញួសមួយអន្ទើ ទុកនៅកាយទុរយោធន៍ នឹងប្រហារតាបានក្លួអង្គ ទុរយោធន៍ស្ទាប់រាលអ្នកដែលចូលផ្គាញ់អភិមន្យុម្នាក់ទៀត គឺសល្យរាជា ព្រះចៅក្រុងមាទ្រព្រះរាជានេះដែរ អភិមន្យុបានកាត់កម្លាំងដោយព្រួញ ពីរបី ដែលបាញ់ចេញទៅមិនខុសទិសម្គាល់ ហើយក៏ក្រោកឧទ្រនាន ចូលតទៅ ។

លំដាប់នោះ ទុះហសាសនៈចេញមកកាំងកងទ័ពមុខ ដើម្បីមិនឲ្យក្រោកចូលទៅ អភិមន្យុឃើញក៏ញញឹមហើយឲ្យកឡើយថា ទ្រង់នេះប្ញស់-គំនិតនិងសកុនិ អួសយកអាណាចក្ររបស់យុធិស្ធិរដោយសបុមុខគ្នា ខ្ទើម ទ្រង់នេះឬដែលចកសិរព្រះនាងទ្រោបទីនិងប្រមាថមើលងាយក្នុងទី ប្រជុំជន ទ្រង់ហៅគឺមថា កញ្ជះកន្ទ្រង់ ឬ ទ្រង់ប្រមាទអរជុនបិតាខ្ញុំ ឬល្អហើយ ទ្រង់ជាសត្រូវជាទីគាប់ចិត្តខ្ញុំក្រៃពេក ខ្ញុំជាបំណុលនៃពាក្យ បដិញ្ញារបស់ទ្រង់ដែរគ្រុំគួនឲ្យរលីងអំពីប្រថពី ។

និយាយដូច្នោះហើយ អ្នកចម្បាំងក៏រម្ងោះក៏ប្រហារទុះហសាសន ដោយកូនសរ ត្រូវដួលដេកលើផ្ទៃធរណី តែក្សត្រក្រុងជាច្រើនអង្គ រត់ទៅជួយរួចអំពីមរណភ័យចំដៃអភិមន្យុ នាំគ្នាសែងចេញទៅអំពីស្នាមយុទ្ធ លោហិតហូរប្រោលបាត់បង់ស្មារតី ។

លំដាប់នោះក្សត្រិយ៍ក្រុង ១ ទៀត ព្យាយាមមកស្កាត់រាំងអភិមន្យុ តែអភិមន្យុគេះខ្វាតចេញទៅ យ៉ាងគេចកំរុយ ១ ក៏ប្រហែលគ្នា ហើយរុកចូលប្រឡូកពាសស្នាមយុទ្ធ ដេញពួកក្សត្រខ្ចាត់ខ្ចាយទៅ គ្មានអ្នកណាទើសឬទល់មុខតដៃបាន ។

លំដាប់នោះជ័យទ្រថ ព្រះចៅក្រុងសន្ធុគប់គិតរួមកម្លាំងគ្នានឹងក្សត្រិយ៍សឹកឯទៀតប្រាំមួយអង្គ ចូលរាំងអភិមន្យុ ទាំងប្រាំពីរអង្គព្រួតគ្នារាំងអភិមន្យុជុំវិញ កូនសរប្រហារទៅអំពីទីគ្រប់ទិសដោយឥតមេត្តាករុណា អភិមន្យុឥតរន្ធត់ស្លុតស្មារតីសោះ បានធ្វើការតស៊ូនឹងសត្រូវគ្នាច្រើន តើនហួសកម្លាំងខ្លួនបានជាច្រើនម៉ោង ក្នុងទីបំផុតទង់រូបមយូររបស់គេ ត្រូវបាញ់ដាច់ធ្លាក់ដល់ដី ត្រូវរថបាក់ខ្ទេចខ្ទីសេះស្លាប់ នាយសារថីត្រូវបាត់ខ្លួនផុត តោះបីដូច្នោះ អភិមន្យុក៏មិនព្រញព្រើ បានវេខ្លួនជុំវិញទទួលសត្រូវទាំង ៧ ផ្លូវ ដែលព្រួតគ្នាចូលរាំង រាងកាយពេញទៅដោយរបួសស្នាកស្នាម កញ្ចោះកញ្ចោះអស់ទាំងសព្វាង្គ លោហិតដាបខ្លួនដាបខ្លួនមុខមាត់ នឹងគ្រឿងតែងកាយ តាំងពីករហូតដល់ជង្គង់ ប្រឡាក់ដៃនឹងអាវុធក្រស់ក្រាំង តោះបីដូច្នោះវីរបុរសកំឡោះតូច ក៏ធ្វើការតស៊ូរឿយទៅ យូរបន្តិចឲ្យមានអាការវិលមុខអស់កម្លាំង ប្រឹងប្រែងទៅមិនរួចទន់ជង្គង់ចុះ ព្រោះលោហិតធ្លាក់ច្រើនណាស់ ដង់ខ្លួនជាដីតែក់ពុងចេញចាករាងកាយក្នុងទីបំផុត គេមិនអាចនឹងទប់ទល់បាន

តទៅ ក៏ដួលចុះអស់សតិអស់ដង្ហើមចេញចូល គេដួលដូចដំរីក្តុកដួលក្នុងព្រៃ ដោយថ្វីដៃព្រានព្រៃកំណាចប្រហារពេលក្នុងអញ្ញារលក់ដូចភ្លើងព្រៃរលត់លិចទៅដូចព្រះអាទិត្យលិចបិទបាំងស៊ុមេរុបព៌ត ងងឹតដូចព្រះចន្ទយាមឧបកគ ។

វេលានោះព្រះអាទិត្យក៏លិចផុតកស៏ ទើបលើកការសង្គ្រាមសម្រាប់ប្រចាំក្នុងថ្ងៃ រង់ចាំវេលាថ្មីតទៅ លំដាប់នោះព្រះចន្ទនិងផ្កាយតារាករក៏រៀងរះឡើងក្នុងនភាល័យប្រទេស ចែងចាំងរស្មីទន់ៗមកត្រូវសពអភិ-មន្យុ ដែលដួលដេកកណ្ដាលទីយុទ្ធនាមុខគួរស្ដាយអ្នកចម្បាំងថ្មីដៃថ្មី ។

អរុណវេលាដែលអភិមន្យុដល់នូវមរណកម្ម នៅឆ្ងាយអំពីគ្នាកំពុងតស៊ូចម្បាំងក្នុងភាគមួយនៃសង្គ្រាមយុទ្ធ ខណៈដែលលើកទ័ពត្រឡប់ចូលបន្ទាយ ស្រាប់តែបានឃើញហេតុភេទអាក្រក់តាមផ្លូវជាច្រើនប្រការ ទើបសន្ទនានឹងនាយសារថីដោយសម្ដីដ៏ស្អោកស្អក ព្រោះមានសេចក្ដីរន្ធត់ត្រប់សង្កត់ថា ក្រិស្ណៈហេតុម្ដេចបានជាហេតុភេទអាក្រក់ មកប្រទះប៉ះពាល់នឹងចក្ខុខ្ញុំ ក្នុងវេលាព្រលប់ថ្ងៃនេះ ហេតុម្ដេចទើបចិត្តខ្ញុំទើបសៅស្ងុតមុខគួរអស្ចារ្យដូច្នេះ ហេតុម្ដេចទើបស្ងាត់ច្រៀបខ្លួទៅតាំងសង្គ្រាមយុទ្ធ លុះចូលទៅជិតបន្ទាយ ក៏ប្រាស្រ័យនឹងក្រិស្ណៈទៀតថា ហេតុម្ដេចបន្ទាយយុធិស្ឋិរ ទើបស្ងាត់ម៉្លេះយប់នេះ ហេតុម្ដេចអភិមន្យុកូនរបស់ខ្ញុំទើបមិនឃើញចេញមកទទួលខ្ញុំ ។

អវជុនសន្ទឹមៗ ឈានជើងចូលទៅក្នុងបន្ទាយយុធិស្ឋិរក្នុងចិត្តរេកស្អាក់ស្ទើរដោយមានសេចក្តីសន្ទិះជាមុន កាលយុធិស្ឋិរក្រឡេកឃើញអវជុនចូលទៅក៏ត្រាស់ថ្លែងរឿងអភិមន្យុ ដែលចេញស៊ូ ទឹងរាជសត្រូវគ្នាច្រើន ត្រូវអារ៉ុងស្លាប់កណ្តាលទីចម្បាំង ។

អវជុនស្រែកចេញមកបានតែមួយម៉ាត់ "អាក្មេងក្មា"ប៉ុណ្ណោះ ក៏ដល់នៅវិសញ្ញីភាព ដួលក្រាបផ្កាប់ផែនដី ហាក់ស្មារតីមួយស្របក់ធំ លុះបើកភ្នែកឡើង នឹកឃើញរឿងនោះក៏ក្រោធញ័រទាំងខ្លួន ទូលយុធិ-ស្ឋិរថា ទ្រង់ជា ជ័យទ្រថ ព្រួតគ្នាធ្វើការកាប់កិនបុត្រទូលបង្គំតែម្នាក់ឯងប្តូ ដែលធ្វើដូច្នោះ ក៏ស្មើដូចជាចោរគ្នា ៧ នាក់ ព្រួតគ្នាសម្លាប់កូនក្មេងម្នាក់ដែលគេអ្នកណាជួយគ្មាន គួរសមហើយប្តូ ក្សត្រិយ៍ប្រព្រឹត្តបន្ទាបខ្លួនចុះកាន់ហីនទោសដោយឥតខ្មាសដូច្នេះ ទំលាយច្បាប់នៃការរក្សាកិត្តិមសក្តិ ជាមន្ទិលមួយហ្នឹងខូចកេរ្តិ៍ឈ្មោះក្សត្រិយ៍ដូច្នេះប្តូ សុំឲ្យឲ្យសេចក្តីក្រោធរបស់បិតាសម្លាប់វាចង់ក្នុងលោកនេះ ទឹងសូមឲ្យពាក្យបណ្តាសានៃបិតាអ្នកមានបុត្រព្រាត់ព្រាកទៅហើយ តាមវាទៅក្នុងលោកឯមុខ ឥឡូវនេះយុធិស្ឋិរអ្នកទ្រង់សីល ចូរស្តាប់ពាក្យបដិញ្ញារបស់ខ្ញុំ សុំកុំឲ្យខ្ញុំបានដល់សេចក្តីសុខនៃសួគ៌ឡើយ ថាបើខ្ញុំសម្លាប់ជ័យទ្រថមិនបានក្នុងថ្ងៃស្អែកនេះ សុំឲ្យវិញ្ញាណរបស់ខ្ញុំទៅកាន់នរយកភូមិ ទឹងទទួល

ទោសទណ្ឌដល់សត្វបាបដែលមានទោសធ្ងន់ៗ នោះ បើមុនអាទិត្យអស្តង្គតថ្ងៃស្អែកនេះ ខ្ញុំសម្លាប់ជ័យទ្រថមិនបានទេ ។

យប់នោះមានការសោកបរិទេវនាការ ក្នុងបន្ទាយបណ្ឌពរហូតរាត្រីកាល លុះថ្ងៃព្រឹកឡើង អរជុនដណ្ដើមយកស័ង្ខសឹកមកផ្លុំខ្លួនឯង សំឡេងទទ្រើនទន្ទ្រាន់ ជាការណ៍សញ្ញាសម្រាប់ពាក្យបដិញ្ញាដ៏ពន្លឹកដែលគេនឹងធ្វើឲ្យសម្រេច លុះលេចទៅក្នុងវេលាមុនអស្តង្គតថ្ងៃនេះ ។

ពួកកោរព បានដឹងពាក្យប្រណិធានអរជុនបានឮសំឡេងស័ង្ខអរជុន ក៏ត្រៀមការតស៊ូយ៉ាងសាហាវកំណាចក្នុងថ្ងៃនោះ អ្នកខ្លះ ដែលសម្លាប់អភិមន្យុ ក៏ព្រួញខ្លួន ជ័យទ្រថមិនហ៊ានចេញទៅទទឹងមុខអរជុន រកផ្លូវគេចទៅនៅក្រោយកងទ័ព ហើយបានស្ដេចទៅឯបាក់ទុរយោធន៍មុនអរុណរះ ទូលថា ពាក្យប្រណិធានរបស់អរជុនថា នឹងយកជីវិតខ្ញុំឲ្យបានក្នុងថ្ងៃនេះ នោះចំពោះឈ្មោះខ្ញុំជាការកែកំហឹងសងសឹករបស់គេ អំពីដើមមកគេមិនដែលពោលពាក្យមុតមាំសម្បើមដូច្នេះ ព្រោះពូជពង្សវង្សត្រកូលរបស់គេត្រូវពួកកោរពសម្លាប់បង់កល់ ៗ ថ្ងៃ ទើបគេឈឺចាប់ខ្លាំងណាស់ក្នុងគ្រានេះ អរជុនជាមនុស្សប្រាកដប្រជា ជាសត្រូវធំក្លារបស់យើង ដូច្នោះពាក្យបដិញ្ញារបស់គេមិនមែនជាពាក្យផ្ដេសផ្ដាស ល្មមយើងនឹងខ្សែកខ្សោយឬធ្វេសប្រហែសបានទេ ខ្ញុំក្រែងថា សេចក្ដីស្លាប់របស់ខ្ញុំនឹងមកដល់ហើយក្នុងគ្រានេះ ។

ទុរយោធន៍ត្រាស់ កុំព្រួយ សម្រាប់ជាតិអ្នកចម្បាំង ដែលនឹងមកប្រារព្ធខ្លាចស្លាប់យ៉ាងនេះមិនគួរ កាលខណៈដង្ហើមចេញចូលរបស់ពាហានោះ ជាការប្រឡែងលេងនឹងសេចក្ដីស្លាប់ខ្ញុំចង់ពោលថា ជំនួសថ្ងៃនេះជាវាទីបំផុតនៃជីវិតទ្រង់នោះ ក៏ក្លាយទៅជាមរណៈនៃអរជុនទៅវិញ ។

ភ័យរបស់ខ្ញុំទៀបចូលមកដល់ហើយណា ។

មិនអីកងទ័ពខ្ញុំទាំងអស់ ខ្ញុំបានផ្ដាំឲ្យចាំការពារទ្រង់ដោយប្រយ័ត្នប្រយែងក្នុងថ្ងៃនេះ ហេតុនោះទ្រង់កុំគាន់ខ្លាចអ្វី ។

លំដាប់នោះត្រែខ្ញុំក៏បន្លឺសព្ទឡើង ដើម្បីឲ្យត្រៀមច្បាំងអរជុនលោតឡើងរថសឹកដោយរួសរាន់ ហើយផ្ដាំក្រិស្ណថា ចូលបរសេះសម្បុរផ្ទៃមេឃរបស់ខ្ញុំឲ្យលឿនជាបំផុត ដែលនឹងបង្ហួរបាន ព្រោះថ្ងៃនេះការងាររបស់ខ្ញុំជាការងាររួសរាន់ទួរស្មែន ខ្ញុំត្រូវធ្វើឲ្យសម្រេចក្នុងថ្ងៃនេះតាមសម្ដីរបស់ខ្ញុំ ប្រសិនជាធ្វើការនោះ មិនសម្រេច ខ្ញុំក៏គាន់លះជីវិតរបស់ខ្ញុំ ។

រថសឹកអរជុនលោតពួតត្រឹកកក្រើកទាំងស្នាមយុទ្ធ រត់ពីចុងស្នាមយុទ្ធម្ខាង ទៅចុងស្នាមយុទ្ធម្ខាងទៀត មានអ្នកលេងពួកកុរុមកទទឹងមុខរថសឹកដែរ អ្នកដំបូង គឺទុរមរស័ន តែអរជុនវាយរត់ប្រឡាតគោតតួនទៅដោយឆាយ ហើយក៏បររថតទៅទៀត ។

លំដាប់នោះទុហសាសន ចូលវាយអជុនដោយដំរីសឹកមួយខ្នាត ធំ ដំរីសឹកគ្រាន់តែឮស្នូររថអជុនក៏ផ្អើលរត់ប្រសាចទៅ អជុនក៏បររថ ខំឃ្មាតរកជ័យទ្រថតទៅទៀត ។

តពីនោះទោណាចារ្យ ចេញមកស្កាត់មុខអជុន ហើយចូល ច្បាំងតតួ តែអជុនសុំខ្ញូនដោយសុភាពថា ចូរឲ្យភ័យដល់កូនសិស្ស ចុះ ថ្ងៃនេះកូនសិស្សមិនទទួលច្បាំងនឹងលោកអាចារ្យទេ ដ្បិតមានអំ- ពល់ទឹងទៅវាយអ្នកសម្លាប់អភិមន្យុបុត្រទ្រង់ឲ្យសម្រេច តាមពាក្យបដិញ្ញា ដ៏ធំដែលបានចេញប្រណិធានទុកនោះ រថសឹកអជុនក៏រត់គេចក្បែរ ទោណាទៅតាមថែវទាហានដែលតម្កល់ជារង់ឥន្ទធ្នូ វាយកម្ចាត់របស់ដែល មកទទឹងមុខវិនាសអស់ទៅ ។

រហូតថ្ងៃនេះ ឮតែស្នូររថសឹកអជុន គ្រឹកទៅគ្រឹកមកខ្ទរខ្ទួរទៅពាំង ស្នាមយុទ្ធ ស្វែងរកតែជ័យទ្រថ មិនប្រទះប៉ះពាល់ក្រិស្ណ ឃើញថាសេះ នឿយណាយណាស់ក៏បញ្ឈប់ ដោះសេះចេញអំពីរថ ឲ្យសម្រាកស៊ី ស្មៅក្រោមម្លប់ឈើមួយ មួយស្របក់ក៏យកមកទឹមវិញ បរជ្រែកទៅ ក្នុងកណ្ដាលកងទ័ពកុរុ ស្ទាតរកតែជ័យទ្រថ តែជ័យទ្រថមិនអើតមុខ ចេញមកឲ្យប្រាកដដល់ចក្ខុអជុនមានក្សត្រិយ៍កុរុឯទៀតជាច្រើនអង្គ មកត ទល់នឹងអជុន តែអង្គខ្លះត្រូវអជុនប្រហារខ្ទេចទៅ អង្គខ្លះមកល ៗ ក៏ គេចបាត់ទៅ ថ្ងៃក៏ទន់ទាបណាស់ទៅហើយ ការដែលស្វែងរកជ័យទ្រថ

មិនប្រែ១ះ អ.ជុនកេកល់ទឹងខូចចិត្តទៅហើយ តែគ្រោះជាគ្រោះនោះ ទទួលអរជុនបោលផ្កែកទៅចុងស្នាមយុទ្ធម្ខាងឯណោះ ឃើញជ័យទ្រថ ប្រថាប់លើរថសឹក កំរើយក្រ.អ៊ីតក្រអាងរឹងប៉ឹង មានទាហានមួយកង រហែហមអមអង្គចាំការពារអរជុនក្រឡេកមើល ទៅព្រះអាទិត្យ ក៏ទៀប អស្តង្គតណាស់ទៅហើយ តែម្ដេចក៏មិនត្រូវបណ្ដោយឲ្យវេលាកន្លងទៅ ទទេ ទោះបីជួរហ្នះក៏មិនមែននឹងចូលទៅវាយលេងបាន ដោយកណិ ដែលជាតួអង្គក្បាលសំខាន់ នៅចាំក្បាលអង្គជ័យទ្រថនោះឃើញអរជុនបររថ ត្រង់ទៅជ័យទ្រថក៏ស្ទុះស្ទាបេញទៅទទួលតស៊ូនឹងអរជុន ដោយបំណង នឹងការពារបង្អង់ឲ្យវេលាអស់ទៅ វេលានៅមានតែពីរម៉ោងទៀតប៉ុណ្ណោះព្រះ អាទិត្យនឹងលិចបើវេលានោះអរជុនធ្វើការមិនសម្រេចសោតតែ ក៏ត្រូវលះ ជីវិតរបស់គេ នេះសេចក្ដីគិតរបស់កណិ ១ គិតទុកតែក្នុងចិត្តជាទុកកាស ហើយ ស ម្លាប់ការពារបាទនឹងអាវុធមករហូតដល់អាយុខ័យ វេលា នេះនឹងកាចអរជុ ឲ្យដួលតាំងឈរកុំឲ្យមានផ្លូវក្រោកឡើងបាន ក្រិស្ណ ឃើញអរជុនធ្លាក់នៅក្នុងចំពន្លៀតពន្លល់ប្រផុតប្រផើយ មិនដឹងជាបកជ័យ ឬមានជ័យព្រះហឫទ័យទ្រង់ជាទុក្ខព្រួយច្រើន ក្នុងខណៈមួយរំពេចនោះ ហាក់បីដូចជាមានទេវតាជំមានអានុភាពមកជួយជួហ្នះ មេឃមីរងងឹតខ្ពល ខ្ទើម--ប់ទិ បិទបាំងមណ្ឌលព្រះទិនករងងឹតសូន្យសុង ទាល់តែ កណិគិតថា ផលពិចំផុតនៃការសញ្ញាអរជុនហើយ គេក៏លើកធ្នូ

ក្នុងរឿងចំបាំងទៀត ដើរចេញអំពីស្នាមយុទ្ធទៅដោយសប្បាយចិត្តជា លាភរស់អរជុនខណៈនោះពពកខ្មួលខ្មៅនោះក៏រសាត់បាត់ទៅ ព្រះអាទិត្យក៏ផ្លេកឡើងមួយរំពេចក្នុងវេលាប្រមាណមួយខណៈ អរជុនកាន់យកធ្នូកាសនោះបានលុកលុយចូលទៅពិឃាតជ័យទ្រថស្លាប់ទៅ ទឹងកន្ទងខបដិញ្ញា ដ៏ធំរបស់គេក៏សម្រេចដោយប្រការដូច្នេះ ។

កាលជ័យទ្រថត្រូវពិឃាតបង់ដូច្នោះហើយ ខាងកុរុក៏ឈប់ជាទម្ងន់ គោងគិតធ្វើការសងសឹកវិញឲ្យគ្រាតែបាន ជាដំបូងដៃដែលកើតចំបាំងគ្នាក្នុងវេលាកត្រី យប់នោះគប់ភ្លើងភ្លឺព្រោងព្រាយខ្លួនទៅទាំងទីចម្បាំង បំភ្លឺមើលគ្នាទៅវិញទៅមក ដើម្បីនឹងធ្វើការប្រឡងជ័យទាន់ក្ដៅចិត្ត ក្របីភ្លឺព្រាកៗ ក្នុងវេលាត្រូវពន្លឺគប់ភ្លើង មុខគ្នាស្រៀវខ្លួន ចាប់ចំបាំងតាំងពីថ្ងៃរហូតដល់យប់ទៀតជា ច្រើនម៉ោង មិនដាច់ស្រេចជាខាងណាមានជ័យ ខាងណាអបកជ័យមែន ទាំងសងខាងបានចំបាំងដោយទោសឥតស្រាកស្រាន្ដ ក្នុងទីបំផុតអស់កម្លាំងរៀងខ្លួន ក៏ព្រមគ្នាឈប់សម្រាកមួយគ្រាសិន ។

គ្រោះអាក្រក់ថ្ងៃនេះធ្វើឲ្យទុរយោធន៍ព្រួយព្រះទ័យជាទម្ងន់ទៀតបានស្ដេចទៅរកទោណាចារ្យ ត្រាស់ថា ខ្ញុំព្រួយធំណាស់ ដ្បិតភីៈថេរទាហានកុរុស្ដើងតិចទៅដោយលំដាប់ ការចំបាំងរបស់យើងថយជ័យដោយលំដាប់ នេះរយ៉ាំងម្ដេច ក៏កាលបានអ្នកចម្បាំងឯករកទីប្រៀប

មិនបាន ដូចយ៉ាងលោកអាចារ្យនេះមកធ្វើការជាមេទ័ពរបស់យើង នៅមកប្រទះការមិនសម្រេចផលដូច្នេះទៀត នៅមានកន្ទាក់កន្ទៀតដូចម្ដេចទៀត ព្រោះចិត្តលោកទន់ ដូចយ៉ាងកីស្នៈ បណ្ដាលឲ្យដៃរបស់លោកទន់ទៅផង ព្រោះក្សត្រិយ៍បាណ្ឌពជាសិស្សរបស់លោក បើជាដូច្នេះពិតយ៉ាងឯណានិមួយ ក្នុងនាមនៃយុត្តិធម៌សម្រាប់ជាតិ ម្ដេចលោកក៏មិនប្រគល់ដំណែងរបស់លោកឲ្យកណ៌ទៅវិញ ។

សេចក្ដីរំជួលដល់កណ៌ បានកើតដល់ទុរយោធន៍កល់ៗគ្រាដែរ កងទ័ពរបស់ទ្រង់ត្រូវរាយបាយទៅ ឬអបជ័យ ទ្រង់ជំនៀលដល់កីស្នៈមិនតិចជាងបីដង ដោយសម្គាល់ថា កីស្នៈយកចិត្តទុកដាក់ខាងបាណ្ឌព ហើយកល់ៗដងទ្រង់គិតនឹងអបលោកកណ៌ឲ្យជាមេទ័ព ក្នុងកាលឥឡូវនេះក៏ទៀត កាលឃើញអរជុនរក្សាពាក្យបញ្ញាទុកបាន ធ្វើការសម្រេចដូចបំណង មិនឲ្យជាអន្តរាយទៅៗ ដោយសេចក្ដីព្យាបាទរបស់សត្រូវ ព្រះហឫទ័យទុរយោធន៍ក៏ស្រងាត់ស្រងូត តែនឹកសង្ឃឹមថា កណ៌នឹងយកជ័យជម្នះមកវិញបាន ដូចទឹកហូរចុះទៅសមុទ្រធំ ឲ្យត្រឡប់ហូរឡើងមកវិញដូច្នោះ តែពេលក្រោយទូលទ្រង់ យ៉ាងដែលកីស្នៈធ្លាប់ក្រាបទូលមកហើយថា "ទុរយោធន៍ បើកងទ័ពរបស់ទ្រង់បែកទៅសោតវាក៏មិនមែនដោយឆ្ងាយ គឺផលនៃអកុសលរបស់ទ្រង់ហ្នឹងឯង កុំបន្ទោសអ្នកស្មាត់ក្នុងការចម្បាំងដ៏មានសក់ស្កូវស្រព្រោងទាំងក្បាល យ៉ាងទូល

ក្នុងរឿងចំបាំងទៀត ដើរចេញអំពីស្នាមយុទ្ធទៅដោយសប្បាយចិត្តជាលាភរស់អរជុំខណៈនោះពពកខ្មៅនោះក៏រសាត់ជាប់ទៅ ព្រះអាទិត្យក៏ផុតឡើងមួយរំពេចក្នុងវេលាប្រមាណមួយខណៈ អរជុំនកាន់យកទុកាសនោះបានលុកលុយចូលទៅពិឃាតជ័យទ្រថស្លាប់ទៅ នឹងកន្ទ្រង់បដិញ្ញា ដីធំរបស់គេក៏សម្រេចដោយប្រការដូច្នេះ ។

កាលជ័យទ្រថត្រូវពិឃាតបង់ដូច្នោះហើយ ខាងកុរុក៏ឈឺចាប់ជាទម្ងន់ គោងគិតធ្វើការសងសឹកវិញឲ្យគ្រាតែបាន ជាដំបូងដៃដែលកើតចំបាំងគ្នាក្នុងវេលារាត្រី យប់នោះគប់ភ្លើងភ្លឺព្រោងព្រាយខ្លួនទៅទាំងទីចម្បាំង បំភ្លឺមើលគ្នាទៅវិញទៅមក ដើម្បីនឹងធ្វើការប្រឡងជ័យទាន់ក្ដៅចិត្ត គ្រប់ភ្លឺព្រោងៗ ក្នុងវេលាត្រូវពន្លឺគប់ភ្លើង មុខគួរស្រៀវខ្លួន ចាប់ចំបាំងតាំងពីថ្ងៃរហូតដល់យប់ទៀតជាច្រើនម៉ោង មិនដាច់ស្រេចជាខាងណាមានជ័យ ខាងណាអបរាជ័យមែន ទាំងសងខាងបានចំបាំងដោយតោសឥតស្រាកស្រាន្ត ក្នុងទីបំផុតអស់កម្លាំងរៀងខ្លួន ក៏ព្រមគ្នាឈប់សម្រាកមួយគ្រាសិន ។

គ្រោះអាក្រក់ថ្ងៃនេះធ្វើឲ្យទុរយោធន៍ព្រួយព្រះទ័យជាទម្ងន់ទៀតបានស្ដេចទៅរកទោណាចារ្យ ត្រាស់ថា ខ្ញុំព្រួយធំណាស់ ដ្បិតអីៈថាទាហានកុរុស្តើងតិចទៅដោយលំដាប់ ការចំបាំងរបស់យើងថយជ័យដោយលំដាប់ នេះវាយ៉ាងម្ដេច ក៏កាលបានអ្នកចម្បាំងឯករកទី.ប្រៀប

មិនបាន ដូចយ៉ាងលោកអាចារ្យនេះមកធ្វើការជាមេទ័ពរបស់យើង នៅមកប្រទះការមិនសម្រេចផលដូច្នេះទៀត នៅមានកន្ទាក់កន្ទៀតដូចម្ដេចទៀត ឬព្រោះចិត្តលោកទន់ ដូចយ៉ាងភីស្មៈ បណ្ដាលឲ្យដៃរបស់លោកទន់ទៅផង ឬព្រោះក្សត្រិយ៍បាណ្ឌពជាសិស្សរបស់លោក បើជាដូច្នេះពិតយ៉ាងឯណានិមួយ ក្នុងនាមនៃយុត្តិធម៌សម្រាប់ជាតិ ម្ដេចលោកក៏មិនប្រគល់ជំណែងរបស់លោកឲ្យកណ៌ទៅវិញ ។

សេចក្ដីរំជួលដល់កណ៌ បានកើតដល់ទុរយោធន៍កល់ៗគ្រាដែរ កងទ័ពរបស់ទ្រង់ត្រូវរាយថយទៅ ឬអបជ័យ ទ្រង់ជំនៀលដល់ភីស្ម មិនគិតជានៃបីផង ដោយសម្គាល់ថា ភីស្មៈយកចិត្តទុកដាក់ខាងបាណ្ឌព ហើយកល់ៗផងទ្រង់គិតខឹងអបលោកកណ៌ឲ្យជាមេទ័ព ក្នុងកាលឥឡូវនេះក៏ទៀត កាលឃើញអរជុនរក្សាពាក្យបដិញ្ញាទុកបាន ធ្វើការសម្រេចដូចបំណង មិនឲ្យជាអន្តរាយទៅៗ ដោយសេចក្ដីព្យាបាទរបស់សត្រូវ ព្រះហឫទ័យទុរយោធន៍ក៏ស្រងាត់ស្រងូត តែទឹកសង្ឃឹមថា កណ៌នឹងយកជ័យជម្នះមកវិញបាន ដូចទឹកហូរចុះទៅសមុទ្រធំ ឲ្យត្រឡប់ហូរឡើងមកវិញដូច្នោះ តែវេលាក្រាបទូលទ្រង់ យ៉ាងដែលភីស្មៈធ្លាប់ក្រាបទូលមកហើយថា "ទុរយោធន៍ បើកងទ័ពរបស់ទ្រង់បែកទៅសោត វាក៏មិនមែនជាឆ្ងាយ គឺផលនៃអកុសលរបស់ទ្រង់ហ្នឹងឯង កុំបន្ទោសអ្នកស្លាប់ក្នុងការចម្បាំងដ៏មានសក់ស្កូវសព្រោងទាំងក្បាល យ៉ាងខ្ញុំ

បង្គំថា ប្រកបដោយអសប្បុរសចិត្តនោះឡើយ ព្រះអង្គនៅជាយុវកុមារណាស់ មិនត្រូវមើលរំលងទាស់ តប្បីទ្រង់ជ្រាបថា អរជុនគ្មានអ្នកឯណាស្មើបានក្នុងយុទ្ធវិជ្ជា នឹងតប្បីទ្រង់ជ្រាបថា ទោណមិនបាច់ឲ្យតៀនក្នុងកិច្ចការជាមុខងាររបស់គេ ដើម្បីនឹងឲ្យទ្រង់ជ្រាបសេចក្តីពិតក្នុងរឿងនេះ ទូលបង្គំសុំពោលប្រណិធានក្នុងទីនេះថា ថ្ងៃនេះ អរជុននឹងស្លាប់ដោយដៃទូលបង្គំ ឬមិនដូច្នោះក៏ទូលបង្គំឯង ។

លុះព្រះទិនករក្តីព្រាងស្វាងពន្លឺ ក៏ចាប់ធ្វើការសង្គ្រាមយ៉ាងក្តៅដែលជាថ្ងៃមុន ឃដោត្កចជាអ្នកមានជ័យដៃក្នុងថ្ងៃនេះ ឈ្មោះនេះជាក្សេ-សៈបុត្រភីម បានធ្វើរំណោកមនឹងសេចក្តីភិតភ័យដល់ពួកទាហានកុរុដោយទោសនៃក្សេសៈ ខ្លួនថ្ងៃនេះមើលទៅហាក់ដូចជាមានឫទ្ធិខុសធម្មតា គឺធ្វើឲ្យគងជន់ កាប់មិនមុតមុខគួរអស្ចារ្យ គេមិនញញើតនឹងរឿងស្លាប់ នឹងការធ្លាក់ទៅជាឈ្លើយនៃសត្រូវយ៉ាងមនុស្សធម្មតា ដែលនឹងកម្រាបគេបាន មានតែអានុភាពទេវតាប៉ុណ្ណោះ កាលគ្រានោះកណ៌ជាទាហានឯកសំខាន់មួយដែរ មានសរជាអស្ចារ្យ ដែលព្រះឥន្ទប្រទានមកតែមួយ ពួកគេតៀនឲ្យយកព្រួសរនោះបាញ់ប្រហារឃដោត្កចក្នុងសំខាន់នោះចេញ កណ៌គោងព្រមតាមសេចក្តីយល់ឃើញរបស់គេពល់គ្នា តែសេចក្តីបំណងរបស់កណ៌គិតជួយព្រួសរនេះទុកនឹងកម្ចាត់អរជុន ដែលខ្លួនតូចកែជាងគេ តែឃដោត្កចមកសម្តែងឫទ្ធិយុកយាក់នៅ

មុខដូច្នេះ ទីនព្រាំងចង់ចល់ពុំបានក៏គោនផ្តិលផ្តួលហាលឲ្យហើយទៅ ដោយទេពអាវុធនោះ កាលយដោក្តួច ត្រូវទេពអាវុធហើយលំដាប់នោះ ការកោឡាហលក្នុងស្នាមយុទ្ធ ក៏ស្ងាត់ច្រៀបដូចគេលត់ តែការស្ងាត់នេះ ដូចយ៉ាងវេលាស្ងាត់មុនផ្គរពាយុលើមេឃ ព្រោះស្ងាត់តែមួយស្របក់ប៉ុណ្ណោះ ក្រោយនោះមិនយូរប៉ុន្មាន ក៏មានការរើផ្ទុំសឹកគ្នាជាថ្មី សន្ធឹកសន្ធាប់ជាងមុនជាពីរភាគ ស្រេចប្រហារយដោក្តួចហើយកណាិក៏ច្រន់ចូលទៅរកសត្រូវហាស់របស់គេ គឺព្រះកជាច្រូបខព្រះពៅក្រុងបញ្ចាលទីងព្រះកជាវិកជ តាំងពីអង្គនេះត្រូវកណាិប្រហារខ្ទេចទៅក្នុងវេលាជាមួយគ្នា សេចក្តីប្រណិធានរបស់គេក៏បានសម្រេចយ៉ាងមុខគួររីករាយសប្បាយចិត្ត ការបង្គាប់បញ្ជារបស់ពោណបាននាំមកនូវជ័យជម្នះ ឬបើយ៉ាងតិចណាស់ ក៏ត្រឹមសងសឹកវិញបាន មិនឲ្យចាញ់ប្រៀបសត្រូវ ។

-5. DEC. 1974
BAPh.../...